# ថ្នាំពេទ្យ របស់របរផ្ទែកពេទ្យ និងឧបករណ៍ផ្សេងៗសម្រាប់អ្នកដែលបានទទួលរងការប៉ះពាល់ដោយសារករណីភ្លើងឆេះនៅក្នុងខោនធី LA

## សំណួរដែលបានសួរជាញឹកញាប់ (FAQs)

### 1. ខ្ញុំបានបាត់បង់ថ្នាំពេទ្យរបស់ខ្ញុំ។ តើខ្ញុំអាចទទួលថ្នាំពេទ្យផ្សេងៗជំនួសមកវិញបានដោយរបៀបណាខ្លះ?

ប្រសិនបើអ្នកបានទទួលរងការប៉ះពាល់ដោយសារករណីបន្ទាន់ទាក់ទងទៅនឹងភ្លើងឆេះព្រៃនោះ អ្នកមានជម្រើសខុសៗគ្នាជាច្រើន ដើម្បីទទួលបានថ្នាំពេទ្យរបស់អ្នកជំនួសមកវិញ។ អ្នកមិនចាំបាច់ត្រូវមានវេជ្ជបញ្ជា ឬដបថ្នាំពេទ្យតាមវេជ្ជបញ្ជារបស់អ្នកនោះទេ។ កំណត់សម្គាល់៖ ប្រសិនបើថ្នាំពេទ្យរបស់អ្នកគឺជាប្រភេទដែលមានការគ្រប់គ្រងតឹងរ៉ឹង (controlled substance) ដូចជាថ្នាំបំបាត់ការឈឺចាប់ប្រភេទខ្លាំងនោះ សូមមើលសំណួរទី 2។

- **ទៅកាន់ឱសថស្ថានមួយ៖**
    - ចូរទូរស័ព្ទ ឬក៏ធ្វើដំណើរទៅកាន់ឱសថស្ថាន (កន្លែងលក់ថ្នាំពេទ្យ) ដែលអ្នកបានទទួលយកថ្នាំពេទ្យតាមវេជ្ជបញ្ជារបស់អ្នកពីពេលដំបូងមកនោះ ប្រសិនបើអាចធ្វើទៅបាន។
    - ប្រសិនបើឱសថស្ថានរបស់អ្នកគឺជាហាងដែលមានសាខាច្រើនទីតាំង ប៉ុន្តែបានបិទឈប់ដំណើរការ ឬក៏អ្នកមិនអាចទៅដល់ទីកន្លែងនោះបានទេ ចូរទៅកាន់ឱសថស្ថានណាមួយក៏បានដែលជាសាខារបស់ហាងនេះ។ សាខាផ្សេងៗនោះអាចពិនិត្យរកកំណត់ត្រារបស់អ្នកនៅក្នុងប្រព័ន្ធកុំព្យូទ័ររបស់ពួកគេ។ ប្រសិនបើអ្នកមិនអាចទៅកាន់ឱសថស្ថានរបស់អ្នកផ្ទាល់ ឬសាខាណាមួយទេនោះ អ្នកអាចទៅកាន់ឱសថស្ថានណាក៏ដោយដែលបើកដំណើរការ។ ពួកគេអាចផ្ទេរវេជ្ជបញ្ជាទាំងឡាយរបស់អ្នកបាន។ ប្រសិនបើពួកគេមិនអាចទាក់ទងទៅកាន់ឱសថស្ថានរបស់អ្នកពីមុនមក ឬមិនអាចទាក់ទងទៅកាន់គ្រូពេទ្យរបស់អ្នកបានទេនោះ ពួកគេប្រហែលជាអាចផ្តល់ជូនថ្នាំពេទ្យគ្រប់គ្រាន់សម្រាប់ឱ្យអ្នកប្រើប្រាស់ រហូតដល់ពេលដែលអ្នកអាចទទួលបានថ្នាំពេទ្យពីប្រភពផ្តល់ជូនជម្មតារបស់អ្នកវិញ។ ចំណុចនេះគឺអនុញ្ញាតឱ្យធ្វើទៅបានក្នុងករណីបន្ទាន់ផ្សេងៗ ដូចជាករណីភ្លើងឆេះនៅក្នុងតំបន់ LA នេះជាដើម។ សូមមើលគេហទំព័រ៖ pharmacy.ca.gov/licensees/state_of_emergency_la.pdf។

កំណត់សម្គាល់៖ ក្នុងអំឡុងពេលមានករណីបន្ទាន់នេះ នៅពេលដែលអ្នកទៅទទួលយកថ្នាំពេទ្យតាមវេជ្ជបញ្ជារបស់អ្នកនោះ អ្នកគួរតែត្រូវការបង់ប្រាក់ដែលនៅសេសសល់ក្រោយក្រុមហ៊ុនធានារ៉ាប់រងបានបង់ខ្លះរួច (co-pay) ដូចជម្មតាតែប៉ុណ្ណោះ។ ចំណុចនេះអនុវត្តសូម្បីតែនៅពេលដែលអ្នកទៅទទួលយកថ្នាំពេទ្យមុនពេលកំណត់ជម្មតា ឬនៅពេលដែលអ្នកទៅកាន់ឱសថស្ថានមួយដែលមិនស្ថិតនៅក្នុងបណ្តាញថែទាំសុខភាពរបស់អ្នកក៏ដោយ ផងដែរ។ សម្រាប់ព័ត៌មានបន្ថែម សូមមើលគេហទំព័រ៖ dmhc.ca.gov/Resources/Newsroom/PressReleases/January9,2025.aspx។

- **ទាក់ទងទៅកាន់ក្រុមហ៊ុនធានារ៉ាប់រងរបស់អ្នក៖** ក្នុងអំឡុងពេលមានករណីបន្ទាន់មួយ ក្រុមហ៊ុនធានារ៉ាប់រងទាំងឡាយអាចផ្ញើថ្នាំពេទ្យតាមវេជ្ជបញ្ជារបស់អ្នកទៅកាន់ឱសថស្ថានមួយ និងអនុញ្ញាតឱ្យទៅទទួលយកថ្នាំពេទ្យមុនពេលកំណត់ ផងដែរ។ ពួកគេក៏អាចជួយដល់អ្នកអំពីរបស់របរផ្ទែកពេទ្យ និងឧបករណ៍ផ្សេងៗរបស់អ្នកផងដែរ។ ចំណុចនេះរួមមានកម្មវិធីធានារ៉ាប់រងសុខភាព Medicare និងផែនការថែទាំសុខភាព Medicare Advantage ទាំងអស់។
    - *ព័ត៌មានសម្រាប់សមាជិករបស់កម្មវិធីធានារ៉ាប់រង L.A. Care៖* https://www.lacare.org/members/health-news-advisories/los-angeles-wildfires-2025-member-services-updates
    - *ព័ត៌មានសម្រាប់សមាជិករបស់កម្មវិធីធានារ៉ាប់រង Health Net៖* https://www.healthnet.com/content/healthnet/en_us/news-center/news-releases/2025-01-08-health-net-providing-special-assistance-members-affected-palisades-fire.html

- *ព័ត៌មានសម្រាប់សមាជិករបស់កម្មវិធីធានារ៉ាប់រង Medicare៖* cms.gov/files/document/dme-emergency-provider-response-support-tool.pdf

- **ទាក់ទងទៅកាន់គ្រូពេទ្យរបស់អ្នក៖** ប្រសិនបើអ្នកអាចទាក់ទងទៅកាន់អ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាព ឬគ្លីនិករបស់អ្នកបាននោះ ចូរប្រាប់ទៅដល់ពួកគេថាអ្នកត្រូវការទៅទទួលយកថ្នាំពេទ្យតាមវេជ្ជបញ្ជាបន្ថែមសម្រាប់ករណីបន្ទាន់។
- **ប្រើប្រាស់សេវាកម្មថែទាំសុខភាពពីចម្ងាយ (telehealth) មួយ** ប្រសិនបើមិនអាចអនុវត្តតាមចំណុចណាមួយខាងលើនេះទេ ឬប្រសិនបើអ្នកត្រូវការវេជ្ជបញ្ជាថ្មីមួយ។ សូមមើលសំណួរទី 4 និងសំណួរទី 5។

## 2. ថ្នាំពេទ្យដែលខ្ញុំបានបាត់នោះគឺជាប្រភេទដែលមានការគ្រប់គ្រងតឹងរ៉ឹង។ តើខ្ញុំអាចទទួលថ្នាំពេទ្យប្រភេទនេះជំនួសមកវិញបានដោយរបៀបណាខ្លះ?

- ប្រសិនបើអ្នកត្រូវការសេវាកម្មផ្នែកការព្យាបាលដោយប្រើប្រាស់ថ្នាំពេទ្យជាជំនួយ (Medication Assisted Treatment/MAT) សម្រាប់បញ្ហាញៀន សូមទាក់ទងទៅកាន់បណ្តាញទូរស័ព្ទផ្នែកការពិគ្រោះយោបល់ទាក់ទងទៅនឹងសេវាកម្ម MAT (MAT Consultation Line) ដើម្បីស្នើសុំវេជ្ជបញ្ជាមួយ។ បណ្តាញទូរស័ព្ទនេះបម្រើការជូន 7 ថ្ងៃក្នុងមួយសប្តាហ៍ ចាប់ពីម៉ោង 8 ព្រឹក ដល់ម៉ោង 12 យប់ តាមរយៈលេខ 213-288-9090។
- ចំពោះថ្នាំពេទ្យជាប្រភេទដែលមានការគ្រប់គ្រងតឹងរ៉ឹង (controlled substances) ផ្សេងទៀត សូមទាក់ទងទៅកាន់អ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពដែលផ្តល់ថ្នាំពេទ្យទាំងនេះតាមវេជ្ជបញ្ជាជូនដល់អ្នកជាទូទៅ។ ប្រសិនបើអ្នកមិនអាចទាក់ទងទៅកាន់ពួកគេបានទេនោះ សូមទៅកាន់មណ្ឌលថែទាំសុខភាពបន្ទាន់ (urgent care) មួយ។

## 3. ខ្ញុំមានការព្រួយបារម្ភអំពីតម្លៃដែលត្រូវបង់សម្រាប់ទទួលថ្នាំពេទ្យរបស់ខ្ញុំជំនួសមកវិញ។ តើមានកម្មវិធីដែលអាចជួយការពារ ឬផ្តល់ជាជំនួយផ្នែកប្រាក់កាសសម្រាប់ប្រើប្រាស់ ដែរឬទេ?

មាន។ ចំណុចនេះអាស្រ័យទៅលើថាអ្នកមានធានារ៉ាប់រងសុខភាពឬទេ។

- ប្រសិនបើអ្នកមានធានារ៉ាប់រងសុខភាព៖
  - ផែនការថែទាំសុខភាពទាំងអស់គឺតម្រូវចាំបាច់ត្រូវចេញថ្លៃចំណាយចំពោះថ្នាំពេទ្យតាមវេជ្ជបញ្ជាដែលមានភាពចាំបាច់សម្រាប់ការព្យាបាល ឧបករណ៍ផ្នែកពេទ្យផ្សេងៗ ហើយនិងរបស់របរនានាសម្រាប់សមាជិកទាំងឡាយដែលបានទទួលរងការប៉ះពាល់ដោយសារករណីភ្លើងឆេះព្រៃ។ ក្នុងអំឡុងពេលមានករណីបន្ទាន់នេះ មិនថាអ្នកទៅទទួលយកថ្នាំពេទ្យរបស់អ្នកតាមវេជ្ជបញ្ជានៅទីណាក៏ដោយ អ្នកគួរតែត្រូវការបង់ប្រាក់ដែលនៅសេសសល់ក្រោយក្រុមហ៊ុនធានារ៉ាប់រងបានបង់ខ្លះរួច (co-pay) តាមធម្មតាតែប៉ុណ្ណោះ។ ចំណុចនេះអនុវត្តសូម្បីតែនៅពេលដែលអ្នកទៅទទួលយកថ្នាំពេទ្យមុនពេលកំណត់ធម្មតា ឬនៅពេលដែលអ្នកទៅកាន់ឱសថស្ថានមួយដែលមិនស្ថិតនៅក្នុងបណ្តាញថែទាំសុខភាពរបស់អ្នកក៏ដោយ ផងដែរ។ សូមមើលគេហទំព័រ៖ dmhc.ca.gov/Resources/Newsroom/PressReleases/January9,2025.aspx។
- ប្រសិនបើអ្នកមិនមានធានារ៉ាប់រងសុខភាព ឬប្រសិនបើថ្នាំពេទ្យរបស់អ្នកគឺមិនមានចេញថ្លៃចំណាយជូនដោយក្រុមហ៊ុនធានារ៉ាប់រងសុខភាពរបស់អ្នក ឬក៏ប្រសិនបើអ្នកមិនមានលទ្ធភាពអាចបង់ប្រាក់ថ្លៃ co-pays បានទេនោះ៖
  - **ប្រើប្រាស់ កម្មវិធីផ្តល់ជំនួយចំពោះវេជ្ជបញ្ជាក្នុងពេលមានករណីបន្ទាន់ (Emergency Prescription Assistance Program/EPAP) ប្រសិនបើមានសិទ្ធិក្នុងការទទួលយកបាន៖** ប្រសិនបើអ្នកមិនមានធានារ៉ាប់រងទេ ហើយអ្នករស់នៅក្នុងតំបន់ជាក់លាក់ផ្សេងៗដែលបាន

ទទួលរងការប៉ះពាល់ដោយសារករណីភ្លើងឆេះមួយនោះ អ្នកអាចនឹងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលបានជំនួយពីកម្មវិធី EPAP។ កម្មវិធី EPAP ជួយផ្តល់ជូនជំនួសមកវិញនូវថ្នាំពេទ្យតាមវេជ្ជបញ្ជា របស់របរផ្នែកពេទ្យ និងឧបករណ៍ផ្នែកពេទ្យដែលអាចយកមកប្រើប្រាស់នៅផ្ទះបានម្តងហើយម្តងទៀត (durable medical equipment) ទាំងឡាយណាដែលបានបាត់បង់ ឬក៏បានខូចខាតដោយសារករណីបន្ទាន់ ឬក្នុងអំឡុងពេលជម្លៀសខ្លួនចេញទៅ ដោយមិនគិតថ្លៃទាំងអស់។ កម្មវិធីនេះក៏មានផ្តល់ជូនថ្នាំបង្ការផ្សេងៗដោយមិនគិតថ្លៃផងដែរ។ ចូរទាក់ទងទៅកាន់បណ្តាញទូរស័ព្ទបន្ទាន់របស់កម្មវិធី EPAP (EPAP Hotline) តាមរយៈលេខ 1-855-793-7470 ដើម្បីពិនិត្យមើលថាអ្នកមានសិទ្ធិក្នុងការទទួលយកបានឬទេ ហើយនិងដើម្បីចុះឈ្មោះ។ សូមស្វែងយល់បន្ថែមនៅលើគេហទំព័រ aspr.hhs.gov/EPAP។

- **ប្រើប្រាស់កម្មវិធីមួយរបស់ខោនធី៖** ខោនធី LA មានផ្តល់ជម្រើសផ្នែកការចេញថ្លៃចំណាយចំពោះការព្យាបាលសម្រាប់ពលរដ្ឋទាំងឡាយដែលមានប្រាក់ចំណូលទាប។ សូមចូលទៅកាន់គេហទំព័រនៃ កម្មវិធីសេវាកម្មផ្នែកសុខភាព (Health Services) របស់ខោនធី LA ឬក៏ទូរស័ព្ទទៅកាន់លេខ **2-1-1**។
- **ពិភាក្សាជាមួយនឹងឱសថការី (អ្នកលក់ថ្នាំពេទ្យ) របស់អ្នក៖** ឱសថស្ថាននានាអាចនឹងមានកម្មវិធីបញ្ចុះតម្លៃ ឬទទួលយកប័ណ្ណបញ្ចុះតម្លៃពីធនធានតាមអនឡាញផ្សេងៗ ដូចជាក្រុមហ៊ុនផ្នែកការថែទាំសុខភាព GoodRx ជាដើម។

## 4. ប្រសិនបើខ្ញុំត្រូវការវេជ្ជបញ្ជាថ្មីមួយនោះ តើខ្ញុំអាចប្រើប្រាស់សេវាកម្មថែទាំសុខភាពពីចម្ងាយ ដើម្បីទទួលបានវេជ្ជបញ្ជាថ្មីនេះដោយរបៀបណាខ្លះ?

- **សេវាកម្មថែទាំសុខភាពដែលមានផ្តល់ជូនដោយផែនការថែទាំសុខភាព៖** ក្រុមហ៊ុនធានារ៉ាប់រងសុខភាពជាច្រើនមានផ្តល់ជូនសេវាកម្មថែទាំសុខភាពពីចម្ងាយ (telehealth) ដោយមិនគិតថ្លៃ ឬគិតថ្លៃទាប។ សូមទូរស័ព្ទទៅកាន់លេខទំនាក់ទំនងនៅលើកាតសមាជិករបស់អ្នក ឬក៏ចូលទៅកាន់គេហទំព័ររបស់ផែនការថែទាំសុខភាពអ្នក។
- **ក្រុមហ៊ុនថែទាំសុខភាពពីចម្ងាយ Teladoc Health** គឺមានផ្តល់ជូនការជួបពិគ្រោះផ្នែកថែទាំសុខភាពពីចម្ងាយ 24 ម៉ោងពេញមួយថ្ងៃ តាមរយៈលេខ 1-855-225-5032។ សេវាកម្មទាំងឡាយរួមមានការព្យាបាលសម្រាប់បញ្ហាសុខភាពនានា ដូចជាការឆ្លងមេរោគតាមផ្លូវដង្ហើម ប្រតិកម្មឬការទាស់បញ្ហាផ្នែកឆ្អឹងប្រហោងក្បាល (sinus) ហើយនិងរោគសញ្ញានានារបស់ជំងឺគ្រុនផ្តាសាយ ឬជំងឺគ្រុនផ្តាសាយធំ។ ក្រុមហ៊ុន Teladoc ក៏អាចជួយផ្តល់ជូនថ្នាំពេទ្យតាមវេជ្ជបញ្ជាណាដែលមិនមែនជាប្រភេទដែលមានការគ្រប់គ្រងតឹងរ៉ឹង (controlled substances) ផងដែរ។ សម្រាប់ព័ត៌មានបន្ថែមសូមចូលទៅកាន់គេហទំព័រ teladochealth.com/info/disaster-hotline។
- **ក្រុមហ៊ុនផ្នែកការថែទាំសុខភាព GoodRx** គឺមានផ្តល់ជូនការជួបពិគ្រោះជាមួយនឹងអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពតាមប្រព័ន្ធអនឡាញដោយមិនគិតថ្លៃ។ ពលរដ្ឋនៃតំបន់ Los Angeles នានាអាចប្រើប្រាស់កូដ LA-GOODRX-CARE សម្រាប់ការពិគ្រោះអំពីបញ្ហាសុខភាពជាច្រើនប្រភេទដោយរួមមានជំនួយក្នុងការទទួលបានថ្នាំពេទ្យតាមវេជ្ជបញ្ជាបន្ថែម ផងដែរ។ សម្រាប់ព័ត៌មានផ្សេងៗ សូមចូលទៅកាន់គេហទំព័រ goodrx.com/care។

## 5. តើខ្ញុំអាចទទួលជំនួយក្នុងការទាក់ទងទៅកាន់ឱសថស្ថាន ឬផែនការថែទាំសុខភាពរបស់ខ្ញុំបានដោយរបៀបណាខ្លះ?

- **ធ្វើដំណើរទៅកាន់មជ្ឈមណ្ឌលផ្តល់ធនធានផ្សេងៗសម្រាប់ពេលមានគ្រោះមហន្តរាយ (Disaster Resource Center/DRC) មួយ។** គិលានុបដ្ឋាយិកានៅតាមទីតាំង DRCs អាចជួយដល់ក្រុមគ្រួសារទាំងឡាយចំពោះផ្នែកព័ត៌មាន ផ្នែកការអប់រំ និងផ្នែកការបញ្ជូនឈ្មោះទាក់ទងទៅនឹងការព្យួរ

ជារម្មផ្សេងៗអំពីការថែទាំសុខភាព។ ពួកគេក៏អាចជួយឱ្យអ្នកអាចទទួលបានថ្នាំពេទ្យផងដែរ តាមរយៈការភ្ជាប់ទំនាក់ទំនងបុគ្គលទាំងនោះទៅកាន់ឱសថស្ថាន (កន្លែងលក់ថ្នាំពេទ្យ) ឬអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពរបស់ពួកគេ។ គិលានុបដ្ឋាយិកានឹងប្រើប្រាស់សេវាកម្មថែទាំសុខភាពពីចម្ងាយរបស់នាយកដ្ឋានសុខភាពសាធារណៈ (Public Health Telehealth Service) ដើម្បីផ្តល់ជូនវេជ្ជបញ្ជាថ្មីសម្រាប់ជួយដល់ក្រុមគ្រួសារទាំងឡាយ រហូតដល់ពេលដែលពួកគេអាចទាក់ទងទៅកាន់គ្រូពេទ្យតាមធម្មតារបស់ពួកគេវិញ ប្រសិនបើត្រូវការ។

**ទីតាំង Westside៖**
UCLA Research Park West
10850 West Pico Blvd.
Los Angeles, CA 90064
*បម្រើការជូនជារៀងរាល់ថ្ងៃ៖ ចាប់ពីម៉ោង 9 ព្រឹក ដល់ម៉ោង 8 យប់។*

**ទីតាំង Eastside៖**
Pasadena City College Community Education Center
3035 East Foothill Blvd.
Pasadena, CA 91106
*បម្រើការជូនជារៀងរាល់ថ្ងៃ៖ ចាប់ពីម៉ោង 9 ព្រឹក ដល់ម៉ោង 8 យប់។*

---

នាយកដ្ឋានសុខភាពសាធារណៈ (Public Health) ចង់ដឹងថាឱសថស្ថាន ឬអ្នកចេញថ្លៃសំណងធានារ៉ាប់រងនានាអនុវត្តតាមច្បាប់នៃការឆ្លើយតបទៅនឹងគ្រោះមហន្តរាយឬទេ។ ប្រសិនបើអ្នកបានបង់ថ្លៃច្រើនជាងការបង់ប្រាក់ដែលនៅសេសសល់ក្រោយក្រុមហ៊ុនធានារ៉ាប់រងបានបង់ខ្លះរួច (co-pay) តាមធម្មតា ឬក៏បានជួបប្រទះនឹងបញ្ហាផ្សេងទៀតនោះ សូមធ្វើការរាយការណ៍តាមរយៈគេហទំព័រ https://forms.office.com/g/BQaAFYsQrA ឬក៏តាមរយៈការស្កេនកូដ QR នេះ។

**សូមចំណាំ**

- **អ្នកគឺមិនមែនមានតែម្នាក់ឯងនោះទេ៖** ទីភ្នាក់ងារសាធារណៈ អង្គការមិនរកប្រាក់ចំណេញ ឱសថស្ថាន និងអ្នកចេញថ្លៃសំណងធានារ៉ាប់រងទាំងឡាយគឺកំពុងសហការជាមួយនឹងគ្នា ដើម្បីជួយឱ្យអ្នកអាចទទួលបានថ្នាំពេទ្យ ក្នុងអំឡុងពេលមានករណីបន្ទាន់។
- **ស្នើសុំជំនួយ៖** ប្រសិនបើអ្នកមានការពិបាកក្នុងការទៅទទួលយកថ្នាំពេទ្យ ឬក្នុងការបង់ប្រាក់ថ្លៃថ្នាំពេទ្យ សូមប្រាប់ឱ្យយើងខ្ញុំបានដឹង។
- **រក្សាទុកព័ត៌មានសំខាន់ៗឱ្យនៅជាប់ខ្លួន៖** សូមឱ្យមានប័ណ្ណសម្គាល់ខ្លួន និងប័ណ្ណព័ត៌មានផែនការថែទាំសុខភាពរបស់អ្នក ប្រសិនបើអាចធ្វើទៅបាន។ ប្រសិនបើអ្នកមិនមានឯកសារទាំងនេះទេ ជាញឹកញាប់ឱសថការី និងគ្លីនិកគឺអាចស្វែងរកព័ត៌មានលម្អិតរបស់អ្នកបាន (ប៉ុន្តែមិនប្រាកដថាអាចរកបានគ្រប់ពេលវេលានោះទេ)។

សម្រាប់ព័ត៌មានបន្ថែម ឬដើម្បីទទួលបានជំនួយ សូមទាក់ទងទៅកាន់**នាយកដ្ឋានសុខភាពសាធារណៈនៃខោនធី Los Angeles (Los Angeles County Department of Public Health)** តាមរយៈលេខ **1-833-540-0473** ឬក៏ចូលទៅកាន់គេហទំព័រ publichealth.lacounty.gov/media/wildfire។ តាមក្រុមការងាររបស់យើងខ្ញុំនៅលើបណ្ដាញសង្គម ដើម្បីទទួលបានព័ត៌មានថ្មីៗទាន់ហេតុការណ៍។

**សូមឱ្យមានសុវត្ថិភាព ហើយសូមចំណាំថាជំនួយគឺអាចរកបាន ដើម្បីធានាថាអ្នកមានថ្នាំពេទ្យផ្សេងៗដែលអ្នកត្រូវការ។**